គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ ៣ ចេញផ្សាយថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១
No. 3 Released on July 19, 2021

អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# ភាគីសំខាន់ៗនៃបរធនបាលកិច្ច

## Main Parties of a Trust




យោងតាមច្បាប់ស្ដីពីបរធនបាលកិច្ច (២០១៩) ភាគីនៃបរធន-បាលកិច្ចជាសំខាន់មាន៣ (បី) គឺបរធនបាលទាយក បរធនបាល និង អត្ថគាហកៈ។

១. បរធនបាលទាយកគឺជាបុគ្គលដែលបានបង្កើត និងកំណត់លក្ខខណ្ឌនៃបរធនបាលកិច្ច និងផ្ដល់ទ្រព្យសម្បត្តិ ឬមូលនិធិដំបូងទៅក្នុងបរធនបាលកិច្ច និងមានសិទ្ធិទទួលព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបរធនបាលកិច្ច ព្រមទាំងតែងតាំង និងបញ្ឈប់បរធនបាល *(ច្បាប់ស្ដីពីបរធនបាលកិច្ច, ២០១៩)* ។

២. បរធនបាលគឺជាបុគ្គលដែលទទួលសិទ្ធិគ្រប់គ្រង និងចាត់ចែងបរធនពីបរធនបាលទាយក សម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។ ជាមួយគ្នានេះ បរធនបាលក៏មានសិទ្ធិទទួលលាភការ ឬកម្រៃនានាក្នុងការគ្រប់គ្រងបរធនបាលកិច្ច ចំណាយក្នុងសកម្មភាពសង្គមស្របតាមគោលបំណងនិងលក្ខខណ្ឌនៃលិខិតបរធនបាលកិច្ច និងស្វែងរកជំនួយឬមូលនិធិដើម្បីជាប្រយោជន៍របស់បរធនបាលកិច្ចផងដែរ *(ច្បាប់ស្ដីពីបរធនបាលកិច្ច, ២០១៩)*។

៣. អត្ថគាហកៈ គឺជាបុគ្គលដែលអាចទទួលផលពីបរធនបាលកិច្ចចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃបរធនបាលកិច្ច លើកលែងតែមានបទប្បញ្ញត្តិផ្សេងទៀត។ អត្ថគាហកៈមានសិទ្ធិទទួលអត្ថប្រយោជន៍ដូចដែលមានចែងក្នុងលិខិតបរធនបាលកិច្ច, ទាមទារឱ្យបរធនបាលបំពេញកាតព្វកិច្ចដែលបានកំណត់ក្នុងលិខិតបរធនបាលកិច្ចនិងតាមបទប្បញ្ញត្តិជាធរមាន ទទួលព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រង និងចាត់ចែងបរធនបាលកិច្ច និងសិទ្ធិផ្សេងទៀតដែលមានចែងក្នុងលិខិតបរធនបាលកិច្ចនិងបទប្បញ្ញត្តិ *(ច្បាប់ស្ដីពីបរធនបាលកិច្ច, ២០១៩)*។

According to the Law on Trust (2019), there are three (3) main parties of a trust: the trust creator, the trustee, and the beneficiary.

1. The trust creator is a person who establishes and determines the conditions of the trust and gives assets or initial funds to the trust and has the right to receive information relating to the trust management as well as the appointment and termination of the trustee *(Law on Trust, 2019).*

2. A trustee is a person who has the right to manage and administer the trust from the trust creator for the benefit of the beneficiary in accordance with the letter of trust or regulations in force. At the same time, the trustee is also entitled to receive benefits or fees for the management of the trust, expenditures on social activities in accordance with the objectives and conditions of the trust, and seek assistance or funds for the benefit of the trust *(Law on Trust, 2019).*

3. The beneficiary is a person who might benefit from the trust from the date of entry into force of the trust, unless other provisions. The beneficiary has the right to receive the benefits as stated in the letter of trust, requires the trustee to fulfill the obligations set out in the letter of trust and in accordance with the provisions in force to receive information related to the management and administration of the trust and other rights stated in trust letter and regulations *(Law on Trust, 2019)*.

**ឯកសារយោង | References**:

- ច្បាប់ស្ដីពីបរធនបាលកិច្ច. (២០១៩).

**អត្ថបទ៖ រតនា រ៉ាឌី | Article: Ratana Rady**

ប្រកាសបដិសេធ៖ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.

www.facebook.com/trustregulatorcambodia
អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh